54
6

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៥១

សាលាដំបូងរាជធានីភ្នំពេញ

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាម ក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣។

សំណុំរឿងព្រហ្មទណ្ឌលេខ:១២៨៤
ចុះថ្ងៃទី០៨-០៧-២០០៨

សាលក្រមលេខ ៣៧ ខ
ចុះថ្ងៃទី២៣-០៣-២០០៩

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញ ថ្ងៃទី២៣-០៣-២០០៩ ដែលមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

**លោក** [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

**លោក** [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

**លោក** [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ១២៨៤ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ដែលមានជនជាប់ចោទ

-ឈ្មោះ [redacted] **ម៉ិនហាវ** ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេ [redacted] ភូមិ៦ សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះ [redacted] ស ប្រពន្ធឈ្មោះ [redacted] មានកូន០៤នាក់ ទោសពីមុនគ្មាន។ សព្វថ្ងៃនៅក្រៅឃុំ ។

-**<u>ត្រូវជាប់ចោទពីបទ:</u>ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ** ប្រព្រឹត្តនៅភូមិបឹងសាឡាង សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧-០៥-២០០៨ តាមបញ្ញត្តិមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

**-មេធាវីលោក [redacted]ចិត្រ លោក[redacted]ម៉ានីន**

-និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គង់** ភេទស្រី អាយុ៥៤ឆ្នាំ មានទីលំនៅផ្ទះលេខ២E ផ្លូវលេខ ២៤៧ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**-មេធាវីលោក[redacted] វីតា.លោក[redacted]ទិ្ធ**

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:</u>

-តាមពាក្យបណ្តឹង ចុះថ្ងៃទី០៨-០៧-០៨របស់ឈ្មោះ[redacted] គង់ ប្តឹងពីឈ្មោះ[redacted]ម៉ិនហាវដោយបញ្ជាក់ថា:កន្លងមកឈ្មោះ[redacted]ម៉ិនហាវតែងតែព្យាយាមលប់ប្រឡាយចាស់ជាច្រើនលើកដែលស្ថិតនៅលើដីកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែអាជ្ញាធរមូលដ្ឋានភូមិ សង្កាត់ និង ប្រជាពលរដ្ឋបានធ្វើការរារាំងមិនឱ្យលប់លើប្រឡាយចាស់នេះទេ ដែល

Scanned by CamScanner

ជាមូលដ្ឋានសំរាប់ទុកបញ្ចៀសទឹកជន់លិចពីខាងលើ។ ប៉ុន្តែឈ្មោះ[redacted]ប៊ុនហាវក៏បានប្រព្រឹត្តសំរេចក្នុងការលប់ប្រឡាយចាស់ដែលនៅក្នុងដីរបស់ខ្លួនតាមបំណង ដោយមកជីកប្រឡាយថ្មីក្រៅដីរបស់ខ្លួនជំនួសវិញ ទង្វើបែបនេះដើម្បីកុំឱ្យខូចប្រយោជន៍របស់ខ្លួនក្នុងការបែងចែកដីជាឡូត៍ ព្រោះកន្លងមកមិនអាចធ្វើទៅបានដោយសារមានប្រឡាយចាស់នៅក្នុងដីដែលត្រូវសាងសង់បុរីទួលសង្កែ។ ការជីកប្រឡាយថ្មីខាងក្រៅថ្មរបស់ខ្លួនបាន ធ្វើឱ្យប៉ះពាល់ដល់ដីកម្មសិទ្ធិ របស់អ្នកដទៃជាច្រើន ដូចយ៉ាងនៅថ្ងៃទី០៧-០៥-០៨ វេលាម៉ោង១:០០យប់ ឈ្មោះ[redacted]ប៊ុនហាវនិងគូកនបានមករំលោភជីកកកាយដីដល់ដីកម្មសិទ្ធិរបស់ខ្លួនដែលមានបណ្តោយប្រហែល១០ម៉ែត្រនិងទទឹងប្រហែល ៨ ម៉ែត្រព្រមទាំងកំទេចរបងរបស់ខ្លួនទាំងស្រុង។ ក្នុងរឿងនេះខ្លួនសុំឱ្យផ្តន្ទាទោសឈ្មោះ[redacted]ប៊ុនហាវនិងគូកនតាមច្បាប់ .សុំសំណងការខូចខាត និង ជម្ងឺចិត្តចំនួន១៥០.០០០ដុល្លាអាមេរិក ដប់ប្រាំម៉ឺនដុល្លា .សុំប្រគល់ដីដែលជាកម្មសិទ្ធិរបស់ខ្លួននិងសុំធ្វើរបងថ្មឱ្យខ្លួនវិញ។

-បានឃើញដីកាសំរេចមិនឃុំខ្លួនលេខ ២៣០១ ចុះថ្ងៃទី១៨-០៨-២០០៨ របស់ចៅក្រមស៊ើបសួរ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៨១ អយក ចុះថ្ងៃទី១៤-០១-២០០៩ របស់ព្រះរាជអាជ្ញាអមសាលាដំបូងក្រុងភ្នំពេញ។

-បានឃើញដីកាជូនរឿងទៅជំនុំជំរះលេខ១១០១ត.ព្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩របស់ចៅក្រមស៊ើបសួរ។

## នាពេលសវនាការ

-តាមការអំណានចម្លើយរបស់ជាប់ចោទឈ្មោះ[redacted]ប៊ុនហាវ ឆ្លើយថា:ឈ្មោះ[redacted] គង់ បានប្តឹងខ្លួនថាជីកប្រឡាយ បណ្តាលឱ្យខូចខាតរបងថ្មគាត់នោះ ពុំជាប់ទាក់ទងនឹងខ្លួនទេ ព្រោះថានៅថ្ងៃកើតហេតុការជីកប្រឡាយដឹកនាំផ្ទាល់ដោយលោកអភិបាលខណ្ឌឬស្សីកែវ[redacted]ហួត ជាប្រធានតាមបញ្ជាណែនាំរបស់ឯកឧត្តម[redacted]ហោ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧត្តុនិយម និង ឯកឧត្តម[redacted]ជុតិមា អភិបាលរាជធានីភ្នំពេញដោយអនុវត្តតាមស្មារតីលិខិតពីរគឺលេខ:១៨៧១សជណ ចុះថ្ងៃទី២៨-១២-២០០៧ និង លិខិតលេខ ៦០៤សជណ ចុះថ្ងៃទី០៥-០៥-២០០៨ របស់ទីស្តីការគណ:រដ្ឋមន្ត្រី។ ក្នុងរឿងនេះខ្លួនជាជនរងគ្រោះមួយដែរ ដោយខ្លួនទទួលសិទ្ធិពីសាលាក្រុងក្នុងការស្ថាបនាលូដែលមានទំហំ 2mx2m មិនទាន់បានធ្វើចប់ត់រោងផង តែត្រូវផ្អាកទៅវិញ។ ក្នុងរឿងនេះខ្លួនសំណូមពរសុំឱ្យតុលាការលើកលែងចោទប្រកាន់ខ្លួន ពីបទចោទប្រកាន់ -សុំឱ្យមិនឱ្យតុលាការឃុំខ្លួន-សុំទាមទារជម្ងឺចិត្តនិងការខាតបង់ពេលវេលាពីឈ្មោះ[redacted] គង់ ចំនួន ១៥ ម៉ឺនដុល្លាអាមេរិក។

-ដើមបណ្តឹងឈ្មោះ[redacted] គង់ បានឆ្លើយថា:ក្នុងការជីកប្រឡាយថ្មីនេះធ្វើឱ្យប៉ះពាល់ដល់កម្មសិទ្ធិរបស់ប្រជាពលរដ្ឋនៅទីនោះជាច្រើន តែដីកម្មសិទ្ធិរបស់ខ្លួនមានការប៉ះពាល់យ៉ាងខ្លាំង ដែលមានប្រវែងប្រហែល៨មx ១០ម។ ក្នុងការជីកកកាយនេះនៅថ្ងៃទី០៧-០៥-២០០៨ បន្តរហូតដល់ម៉ោង១យប់បណ្តាលឱ្យរបងផ្ទះត្រូវបំផ្លាញដោយសារគ្រឿងចក្រ។ ដើម្បីផលប្រយោជន៍របស់ខ្លួនក្នុងការពុះដីឡូត៍បុរីទួលសង្កែរបស់ខ្លួន ទើបឈ្មោះ[redacted] ប៊ុនហាវ ប្រព្រឹត្តបែបនេះ ដោយគ្មានសេចក្តីសំរេចណាមួយអនុញ្ញាតិឱ្យឈ្មោះ[redacted]ប៊ុនហាវ ជីកប្រឡាយថ្មីទៅប៉ះពាល់ដីកម្មសិទ្ធិរបស់

Scanned by CamScanner

ខ្លួននិងដីកម្មសិទ្ធិអ្នកដទៃនោះទេ ។

-នៅថ្ងៃទី២០-១១-២០០៦មានលិខិតជាបមកលោក[redacted]ប៊ុនហាវ ដោយអភិបាលរាជធានីភ្នំពេញ ដោយអនុញ្ញាតិឱ្យលោក[redacted]ប៊ុនហាវ ស្ថាបនាប្រឡាយបេតុងអាម៉េត្រប ស្ថិតនៅក្នុងដីកម្មសិទ្ធិរបស់លោ[redacted]ប៊ុនហាវ តែប៉ុណ្ណោះ ។ ទង្វើរបស់លោក[redacted] ប៊ុនហាវ មិនត្រឹមតែបំពានលើសេចក្តីសំរេចប៉ុណ្ណោះទេ ថែមទាំងមកបំពានលើដីកម្មសិទ្ធិរបស់ខ្លួនទៀតផង ។ នៅថ្ងៃទី១៤-០៥-២០០៨ ខ្លួនបានប្តឹងទៅសាលាក្រុងភ្នំពេញពីការបំផ្លិចបំផ្លាញរបងនិងជីកកកាយដីរបស់ខ្លួន លុះដល់ថ្ងៃទី១១-០៦-០៨ លិខិតរបស់សាលាក្រុងភ្នំពេញដែលមានចុះហត្ថលេខាលោកអភិបាលក្រុង ដែលមានខ្លឹមសារបញ្ជាក់ថា ចំពោះសំណើសុំជួយដោះស្រាយនូវសំណងខូចខាត ដែលបណ្តាលមកពីអាជ្ញាធរខណ្ឌឫស្សីកែវនិងក្រុមហ៊ុន[redacted]នហាវ យកគ្រឿងចក្រមកកកាយដីនិងវាយកំទេចរបងថ្មី ជីកប្រឡាយប៉ះពាល់បណ្ណ័សំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ស្ថិតនៅដីឡូត៍លេខ៩៥ ផ្លូវ១៧៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ក្នុងខណ្ឌឫស្សីកែវនោះ សូមលោកស្រីដាក់ពាក្យប្តឹងទៅតុលាការដើម្បីដោះស្រាយតាមច្បាប់ ។ ខ្លួនសុំតុលាការផ្តន្ទាទោសជននេះទៅតាមច្បាប់ ទាមទារដី ទាមទារឱ្យធ្វើសំណង់ការខូចខាត និង ជម្ងឺចិត្តចំនួន ០១ ដុល្លាអាមេរិក (មួយម៉ឺនដុល្លាអាមេរិក) ។

-សាក្សីឈ្មោះ[redacted]វណ្ណី បានឆ្លើយថា: ខ្លួនបានស្បថរួចហើយ ខ្លួនត្រូវជាជន្មនឹងឈ្មោះ[redacted]តង់ កន្លងមកសាលាក្រុងភ្នំពេញមិនបានជូនដំណឹងដល់ពូកខ្លួនអំពីការជីកប្រឡាយនេះទេ ។ នៅពេលយប់វេលាម៉ោងប្រហែល៩ ក្រុមរបស់លោក [redacted]ប៊ុនហាវ បានជីកប្រឡាយចូលក្នុងដីរបស់ឈ្មោ[redacted]តង់ នៅជ្រុងខាងកើតនិងជ្រុងខាងត្បូងតែម្តង ។ ពេលកើតហេតុខ្លួនពុំបាននៅទីនោះទេ កន្លែងដែលជីកប្រឡាយសព្វថ្ងៃនេះគ្រាន់តែជីកបើកមុខដើម្បីធ្វើការសាងសង់តែប៉ុណ្ណោះ ហើយកន្លែងនោះថាជាប្រឡាយក៏បានព្រោះបានចាក់ដី ។

-មេធាវី[redacted]រិទ្ធិ ធ្វើសេចក្តីសន្និដ្ឋាន: ប្រឡាយនេះដំបូងឡើយនៅក្នុងដីរបស់[redacted]ប៊ុនហាវទេ តែក្រោយមកឈ្មោ[redacted]ប៊ុនហាវ បានមកសុំអ្នកស្រី[redacted]តង់ ជីកប្រឡាយលើដីរបស់គាត់ តែគាត់ពុំព្រម ។ លុះដល់យប់ថ្ងៃទី០៥-០៧-២០០៨ មានគេទៅជីកប្រឡាយលើដីរបស់អ្នកស្រី[redacted]តង់ ក្រោយពីការជីកនេះហើយអ្នកស្រី[redacted] តង់ បានប្តឹងទៅសាលាក្រុងភ្នំពេញ ហើយសាលាក្រុងភ្នំពេញ បានឱ្យអ្នកស្រីប្តឹងមកតុលាការ ។ ចំពោះការឆ្លើយរបស់សាលាខណ្ឌឫស្សីកែវថា: ការជីកប្រឡាយពេលយប់នេះជាការបន្ទាន់ គឺពុំត្រឹមត្រូវទេ ព្រោះថាមុននឹងការជីកប្រឡាយនេះ បើយល់ឃើញថាមានប៉ះពាល់ដល់ដីរបស់អ្នកស្រី[redacted]តង់មែននោះ ត្រូវតែជូនដំណឹងដល់គាត់ជាមុនសិន ។ ខ្លួនសំណូមពរសុំផ្តន្ទាទោសជនជាប់ចោទយ៉ាងតឹងរឹងបំផុត ចំពោះសំណង និង ការខូចខាតខ្លួនសុំដូចកូនក្តីរបស់ខ្លួនសុំដែរ ។

-មេធាវី[redacted]កា ធ្វើសេចក្តីសន្និដ្ឋាន:របងដែលបានបំផ្លាញនោះពិតជារបស់អកស្រី[redacted]ឈុំអែន ជាស្ថិតនៅក្នុងដីឡូត៍របស់គាត់ ដែលមានបណ្ណ័សំគាល់សិទ្ធិត្រឹមត្រូវ ហើយរបងនេះបានធ្វើតាំងពីឆ្នាំ២០០៤មកម្ល៉េះបើគាត់សង់ចូលផ្លូវសាធារណៈមែន ត្រូវមានការហាមឃាត់ពីអាជ្ញាធរមូលដ្ឋានហើយ ។ ការសុំទៅសាលាក្រុងធ្វើប្រឡាយអាមេរបស់លោក[redacted]ប៊ុនហាវ គឺសុំធ្វើតរបលើប្រឡាយចាស់ទេពុំមានអនុញ្ញាតិឱ្យគាត់ជីកប្រឡាយថ្មីទេ ។ចំណែកគ្រឿង

Scanned by CamScanner

ចក្រជីកតីរបស់លោក[redacted]ប៊ុនហាវទាំងអស់ ជនល្មើសគឺពិតជាលោក[redacted]ប៊ុនហាវ ។ ប្រឡាយចាស់គឺលោក[redacted]ប៊ុនហាវ បានលប់ចោលទៅហើយដើម្បីបំរើផលប្រយោជន៍របស់គាត់ ហើយគាត់បានមកជីកប្រឡាយថ្មីនៅក្នុងដីរបស់អ្នកស្រី[redacted]គង់ ។ ខ្ញុំសុំឱ្យតុលាការពិចារណាលើលិខិតរបស់សាលាក្រុង និង បណ្ដឹងតាល់សិទ្ធិរបស់អ្នកស្រី[redacted] គង់ សុំតុលាការផ្ដន្ទាទោសតាមច្បាប់ ។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានៈសុំរក្សាបទចោទប្រកាន់នៅដដែល និង សុំលោកចៅក្រមជំនុំជំរះសំរេចតាមច្បាប់ចុះ ។

-មេធាវី[redacted]វិចិត្រ ធ្វើសេចក្ដីសន្និដ្ឋានៈកូនក្ដីខ្ញុំត្រូវបានចោទប្រកាន់ដោយអយុត្តិធម៌ពីអ្នកស្រី[redacted]គង់ ថាបានទៅជីកប្រឡាយចូលទៅដីរបស់គាត់ ការជីកប្រឡាយកាលពីថ្ងៃទី០៧-០៥-២០០៨ គឺអនុវត្តតាម សជណ របស់ ទីស្ដីការគណៈរដ្ឋមន្ត្រី ដឹកនាំដោយអភិបាលខណ្ឌឫស្សីកែវ ការជីកប្រឡាយនេះដើម្បីបំរើប្រយោជន៍សាធារណៈ មានការប៉ះពាល់ជាច្រើនគ្រួសារ តែប្រជាជនផ្សេងទៀតពុំប្ដឹងតវ៉ាទេព្រោះគេយល់ ។ ម្យ៉ាងទៀតកូនក្ដីខ្ញុំខ្ញុំគ្មានអំណាចអ្វីមោបញ្ជាអភិបាលខណ្ឌ និង ក្រសួងធនធានទឹកទេ ការចោទប្រកាន់នេះពុំមានទំនាក់ទំនងគ្នាទេ ការប្ដឹងនេះពុំមានភស្ដុតាងទេ ការទទួលខុសត្រូវលើរឿងនេះគឺអាជ្ញាធរ ។ ចំពោះការលើកឡើងរបស់លោកមេធាវី[redacted]តាថា លោក[redacted] ប៊ុនហាវ បានលប់ប្រឡាយចាស់ចោល ហើយមកជីកប្រឡាយថ្មីលើដីរបស់កូនក្ដីគាត់នោះ ខ្ញុំសុំឱ្យគាត់រកភស្ដុតាងឱ្យឃើញលើចំណុចនេះ ។ ខ្ញុំសំណូមពរសុំឱ្យតុលាការលើកលែងចោទប្រកាន់ដល់កូនក្ដីខ្ញុំដោយអនុគ្រោះ ។

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹង

-ក្រោយពីបានស្ដាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្ដុតាង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្ដឹង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យនិងពិចារណាត្រឹមត្រូវតាមច្បាប់

**សាលាដំបូងរាជធានីភ្នំពេញ**

-យល់ឃើញថាជនជាប់ចោទឈ្មោះ[redacted] ប៊ុនហាវ បានឆ្លើយបដិសេធថាៈការប្ដឹងចោទរបស់ឈ្មោះ[redacted] គង់ ថាខ្ញុំជាអ្នកជីកប្រឡាយបណ្ដាលឱ្យខូចខាតរបងថ្មគាត់នោះ គឺពុំពាក់ពន្ធ័នឹងខ្ញុំទេ ព្រោះថានៅថ្ងៃកើតហេតុការជីកប្រឡាយនេះដឹកនាំដោយលោកអភិបាលខណ្ឌឫស្សីកែវ[redacted] ហួត ដែលមានការណែនាំពីរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧត្តុនិយមនិងអភិបាលរាជធានីភ្នំពេញ ដោយអនុវត្តតាមស្មារតីលិខិតលេខ១៨៧១សជណ ចុះថ្ងៃទី២៨-១២-២០០៧ និង លិខិតលេខ៦០៤ សជណ ចុះថ្ងៃទី០៥-០៥-២០០៨របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

Scanned by CamScanner

-យល់ឃើញថាការបំភ្លឺជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១៤-០៨-២០០៨ របស់លោកអភិបាលខណ្ឌឫស្សីកែវ ថាៈការជីកប្រឡាយបើកផ្លូវរំដោះទឹកស្អុយនៅសង្កាត់ទួលសង្កែ គីឡូម៉ែត្រលេខ៦ ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ដឹកនាំដោយសាលាខណ្ឌឫស្សីកែវ អនុវត្តតាមស្មារតីបញ្ជារបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧត្តុនិយម និង ឯកឧត្តមអភិបាលរាជធានីភ្នំពេញ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ចៀសផុតពីការលិចលង់និងអនុវត្តតាមគំរោងរបស់សាលាក្រុងភ្នំពេញនិងរាជរដ្ឋាភិបាល ។ការជីកប្រឡាយនេះមិនពាក់ព័ន្ធនឹងលោក[redacted] ប៊ុនហាវទេ ។ ការដឹកនាំកម្លាំងចុះធ្វើពេលយប់នេះ ព្រោះជាបទបញ្ជាឱ្យជីករំដោះទឹកជាបន្ទាន់ ដោយមិនរង់ចាំពេលវេលាទេ ការជីកនេះប៉ះរបងនិងប៉ះដីរបស់ប្រជាពលរដ្ឋជាច្រើនគ្រួសារ ពុំមែនប៉ះតែរបងរបស់ឈ្មោះ[redacted] គង់ម្នាក់ឯងនោះទេ ។

-យល់ឃើញថានាពេលសវនាការនេះសាក្សីឈ្មោ[redacted]វណ្ណី បានឆ្លើយថា កន្ទុងមកពូកខ្ញុំនពុំដែលបានទទួលដំណឹងពីសាលារាជធានីភ្នំពេញអំពីការជីកប្រឡាយនេះទេ ហើយនៅយប់កើតហេតុនោះក្រុមរបស់លោក[redacted] ប៊ុនហាវ ពិតជាបានជីកប្រឡាយចូលទៅក្នុងដីរបស់អ្នកស្រី[redacted]គង់ នៅជ្រុងខាងកើតនិងជ្រុងខាងត្បូងពិតប្រាកដមែន

-យល់ឃើញថាការប្ដឹងរបស់ឈ្មោះ[redacted]គង់ថាៈនៅថ្ងៃទី០៧-០៥-២០០៨ វេលាម៉ោង១:០០យប់ ឈ្មោះ[redacted]ប៊ុនហាវ និង គូកនបានមករំលោភជីកកកាយដីកម្មសិទ្ធិរបស់ខ្ញុំន ដែលមានបណ្ដោយប្រហែល១០ម៉ែត្រនិងទទឹងប្រហែល៨ម៉ែត្រ បណ្ដាលឱ្យមានការខូចខាតរបងខ្ញុំនទាំងស្រុង ។

-យល់ឃើញថាការប្ដឹងរបស់ឈ្មោះ[redacted]ង់ ទាមទារដី សុំឱ្យធ្វើរបងថ្មឡើងវិញ និង ទាមទារសំណងការខូចខាតនិងជម្ងឺចិត្តចំនួន ១០.០០០ដុល្លារអាមេរិកនោះ តប្បីតុលាការលើកយកមកពិចារណា ។

-នាពេលសវនាការនេះតំណាងអយ្យការនៅតែធ្វើការចោទប្រកាន់ទៅលើឈ្មោ[redacted]ប៊ុនហាវ ពីបទធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃដដែល ។

-ជនជាប់ចោទឈ្មោះ[redacted]ប៊ុនហាវ បានសុំចៅក្រមមិនឱ្យឃុំខ្លួនជាបណ្ដោះអាសន្ន ។

-យល់ឃើញមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោ[redacted]ប៊ុនហាវ ពីបទៈធ្វើឱ្យខូចខាតដោយចេតនាទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ កាលពីថ្ងៃទី០៧-០៥-២០០៨ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ

## វិនិច្ឆ័យសេចក្ដី

១-ផ្ដន្ទាទោសឈ្មោ[redacted] **ប៊ុហាច** ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **០២ឆ្នាំ ពីរឆ្នាំ** តែទោសនេះត្រូវព្យួរមានរយៈពេលសាកល្បង ០៥ឆ្នាំ គិតពីសាលក្រមស្ថាពរ ពីបទៈធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧-០៥-២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៥២ មាត្រា៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

Scanned by CamScanner

54/1

២-ឲ្យឈ្មោះ [redacted] **ប៊ុនហ្វាច** សងសំណងការខូចខាតនិងជម្ងឺចិត្តជាប្រាក់ចំនួន ៤០.០០០.០០០រៀល សែសិបលានរៀល ទៅដើមបណ្តឹងឈ្មោ[redacted] តង់ នៅពេលសាលក្រមចូលជាស្ថាពរសំណើលើសពីនេះបដិសេធចោល ។

ក្នុងករណីជនជាប់ចោទគ្មានប្រាក់សងធនទណ្ឌទេ ត្រូវអនុវត្តការដាក់បង្ខំដល់រូបកាយតាមក្រមនីតិវិធីព្រហ្មទណ្ឌ

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹង មេធាវីដើមបណ្តឹង មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើលផ្លូវប្តឹងទាស់និងប្តឹងឧទ្ធរណ៍ក្នុងកំឡុងច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ** |
| **ហត្ថលេខា:** [redacted] | **ហត្ថលេខា:** [redacted] |

---

| | |
|---|---|
| **បានឃើញ** | បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។ |
| **ចៅក្រមជំនុំជំរះ** | រាជធានីភ្នំពេញ ថ្ងៃទី០6 ខែ មេសា ឆ្នាំ២០០៩ |
| | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |